# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : **អង់គ្លេស**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2011, 12:16
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានការគ្រប់គ្រងសវនាការ

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន

លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- អនុលោមតាមវិធាន៨៥, ៨៧ និង៩១(១) និងដើម្បីជាប្រយោជន៍នៃការរៀបចំសវនាការប្រកបដោយប្រសិទ្ធភាព សហព្រះរាជអាជ្ញាសូមដាក់សំណើចំនួនបីដូចខាងក្រោម ជូនទៅអង្គជំនុំជម្រះសាលាដំបូង ក្នុងនោះមាន៖

(1) ដាក់ចេញ នៅមុនថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ នូវដីកាបណ្តោះអាសន្នសម្រាប់កោះហៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ ពាក់ព័ន្ធនឹងផ្នែកដំបូងនៃការជំនុំជម្រះនៅដំណាក់កាលទីមួយ។ កំណត់វិសាលភាព និងពេលវេលានៃផ្នែកទីពីរ និងកំណត់អត្តសញ្ញាណសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីសក្តានុពល សម្រាប់ផ្នែកទីពីរនេះ យ៉ាងហោចណាស់ សម្រាប់រយៈពេលដែលគ្របដណ្តប់ក្នុងកិច្ចជំនុំជម្រះនៅដំណាក់កាលទីពីរ គឺថ្ងៃទី១០ ខែមករា ដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២។

(2) ដកឈ្មោះអ្នកជំនាញមួយរូប និងសាក្សីបួនរូប ដែលពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចេញពី *ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង០០២*[1] និង

(3) ផ្តល់រយៈពេលមួយសប្តាហ៍សម្រាប់សវនាការ ក្នុងគោលបំណងផ្តល់សេចក្តីសន្និដ្ឋានផ្ទាល់មាត់ស្តីពីការទទួលយកឯកសារនានា រយៈពេលប្រាំថ្ងៃ ក្នុងអំឡុងពេលពីថ្ងៃទី៦ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២។

២- សហព្រះរាជអាជ្ញាសូមគាំទ្រពេញទំហឹងចំពោះសារៈសំខាន់នៃកិច្ចប្រជុំក្រៅផ្លូវការស្តីពីការរៀបចំសវនាការ និងចំពោះការផ្តល់លក្ខណៈងាយស្រួលពីសំណាក់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពន្លឿនដំណើរការនីតិវិធី បើទោះជាសំណើទាំងនេះតម្រូវឲ្យមានដីការបស់អង្គជំនុំជម្រះដែលកិច្ចប្រជុំក្រៅផ្លូវការស្តីពីការរៀបចំសវនាការមិនអាចត្រូវបានប្រើប្រាស់ សម្រាប់គោលបំណងនេះក៏ដោយ។

## II. សំណើសុំដីកាបណ្តោះអាសន្នកោះហៅសាក្សីសម្រាប់សវនាការលើកទីពីរ ចាប់ពីថ្ងៃទី១០ ខែមករា រហូតដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២

---

1. **E131/1.1** ឧបសម្ព័ន្ធសម្ងាត់ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១។

៣- នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ប្រមាណជិតដប់មួយខែកន្លងទៅនេះ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី[2] រួមជាមួយនឹងសំណើបង្គាប់ឲ្យកោះហៅសាក្សីចូលផ្តល់សក្ខីកម្មក្នុងសវនាការដែលបានស្នើសុំ[3]។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់ ("SLO") របស់អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងជូនដំណឹងភ្លាមដល់ភាគីទាំងឡាយនៃក្រុមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវកោះហៅផ្តល់សក្ខីកម្មក្នុងសវនាការសំណុំរឿង០០២/១។ ដើម្បីចៀសវាងការលំបាកក្នុងការរៀបចំកាលវិភាគ មន្ត្រីច្បាប់ជាន់ខ្ពស់បានណែនាំថា ក្រុមបន្ទាប់នឹងមិនលើសពីប្រាំនាក់ទេ[4]។ នៅក្នុងកិច្ចប្រជុំដដែលនោះ អ្នកតំណាងរបស់សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ក.ស.ព ត្រូវការការជូនដំណឹងជាមុននៃចំនួនសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានកាន់តែច្រើនដូចដែលអាចធ្វើបាន សម្រាប់ការរៀបផែនការ និងការត្រៀមខ្លួនបានល្អ។

៤- សហព្រះរាជអាជ្ញានៅតែបារម្ភថានឹង "ត្រូវផ្តល់ឲ្យភាគីនូវការជូនដំណឹង*គ្រប់គ្រាន់*អំពីការកំណត់កាលបរិច្ឆេទនាពេលអនាគត សម្រាប់កិច្ចដំណើរការនីតិវិធី ក្នុងនោះមានការបញ្ជាក់អំពីកាលបរិច្ឆេទសម្រាប់សាក្សី និងអ្នកជំនាញ ដែលត្រូវកោះហៅឲ្យផ្តល់សក្ខីកម្ម[5]"។ ជាពិសេស សាក្សីដែលត្រូវផ្តល់សក្ខីកម្មអំពីរចនាសម្ព័ន្ធនៃប.ក.ក ឬកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទ[6]។ ក្រៅពីកិច្ចការរៀបចំសំខាន់ៗ និងពេលវេលាត្រូវការសម្រាប់ការពិគ្រោះយោបល់ និងការសម្របសម្រួលឲ្យបានសម ស្រប រវាងបុគ្គលិកជាតិ និងអន្តរជាតិ ក្នុងការិយាល័យរបស់ខ្លួន សហព្រះរាជអាជ្ញារំពឹងថានឹងមានតម្រូវការដាក់ឯកសារជាច្រើនទាក់ទងនឹងសាក្សីទាំងនោះ ដែលតម្រូវឲ្យមានដំណាក់កាលរៀបចំជាក់ស្តែងមួយចំនួន ដើម្បីជាប្រយោជន៍នៃការប្រើប្រាស់ពេលវេលាប្រកបដោយប្រសិទ្ធភាពសម្រាប់ជំនុំជម្រះក្តី។

---

2 **E9/4** បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៤, និងទី៥ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។

3 **E9/4.1** ឧបសម្ព័ន្ធ១៖ សំណើបង្គាប់ឲ្យសាក្សីចូលបង្ហាញខ្លួនក្នុងសវនាការ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។

4 កំណត់សម្គាល់អ្នកតំណាងរបស់ ក.ស.ព មានវត្តមាននៅក្នុងកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១១។

5 **E138** ដីកាកំណត់កាលវិភាគនៃដំណើរការសវនាការ (អង្គហេតុ និងលំដាប់នៃការកោះហៅសាក្សី) សម្រាប់រយៈពេលពីថ្ងៃទី១៧ ខែសីហា ដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ ត្រង់ទំព័រ៣ [គូសបញ្ជាក់បន្ថែម]។

6 **E124/7.1** ឧបសម្ព័ន្ធ, ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។ រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា និង របបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទរួមមាន ការចូលរួមអំណាចក្នុងបញ្ហាដែលកំណត់ដោយអង្គជំនុំជម្រះសម្រាប់សវនាការដំបូង។

៥- សហព្រះរាជអាជ្ញាទទួលស្គាល់ទាំងស្រុងចំពោះឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ក្នុងការផ្លាស់ប្តូរលំដាប់លំដោយនៃការកោះហៅសាក្សី ឬសេចក្តីសម្រេចកំណត់កាលបរិច្ឆេទ ប៉ុន្តែសូមស្នើឱ្យអង្គជំនុំជម្រះសម្រេចជាបន្ទាន់នូវដីកាបណ្តោះអាសន្នកោះហៅសាក្សីដែលនៅសេសសល់ សម្រាប់ការជំនុំជម្រះក្តីដំណាក់កាលទីមួយនៃសំណុំរឿង០០២/១ ជាពិសេស ឱ្យបានមុនពេលវិសមកាលរបស់តុលាការក្នុងខែធ្នូ និងមករា ដែលច្បាស់ណាស់ថា បុគ្គលិករបស់សហព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្តី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គជំនុំជម្រះឈប់សម្រាកជាក់ជាមិនខាន។

## III. សំណើសុំដកចេញអ្នកជំនាញចំនួនមួយរូប និងសាក្សីចំនួនបួនរូប

៦- កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចស្តីពីសម្បទាចូលរួមក្នុងការជំនុំជម្រះក្តីរបស់ អៀង ធីរិទ្ធ ដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចបំបែកបទចោទប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង០០២ អនុលោមតាមវិធាន ៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុង[7]។

៧- ដូចបានលើកជូនមន្ត្រីច្បាប់ជាន់ខ្ពស់រួចហើយ សហព្រះរាជអាជ្ញាបានពិនិត្យមើលឡើងវិញ នូវបញ្ជីសាក្សី និងអ្នកជំនាញ ដើម្បីកំណត់អត្តសញ្ញាណថាអ្នកណាដែលត្រូវបានស្នើជាបឋម ដោយសហព្រះរាជអាជ្ញា (**លេខ ១**) ឬដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ (**ពីលេខ ២ ទៅលេខ ៤**) ទាក់ទងនឹង អៀង ធីរិទ្ធ។ ទាក់ទិននឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី សហព្រះរាជអាជ្ញាស្នើឱ្យដកចេញអ្នកជំនាញ និងសាក្សីចំនួនបួនរូបខាងក្រោមនេះ ចេញពីបញ្ជីបច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូងនៃបញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ការជំនុំជម្រះក្តីដំណាក់កាលទី១ ក្នុងសំណុំរឿង ០០២៖

(1) TCE-27 (អ្នកជំនាញទាក់ទងនឹងប្រព័ន្ធសុខាភិបាលកម្ពុជាប្រជាធិបតេយ្យ);

(2) TCW-18 ;

(3) TCW-90 ;

[7] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១។

(4) TCW-600; និង

(5) TCW-778.

## IV. សំណើសុំកំណត់កាលបរិច្ឆេទសម្រាប់សវនាការផ្ទាល់មាត់ ស្តីពីភាពអាចទទួលយកបាននៃឯកសារនៅក្នុងសវនាការវគ្គទីពីរ ក្នុងអំឡុងពេលសប្តាហ៍ពីថ្ងៃទី៦ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២

៨- នៅក្នុងអនុស្សរណៈរបស់ខ្លួនចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីបញ្ជាក់មិនឲ្យហួសពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ ថាប្រសិនបើមាន តើឯកសារដែលនៅសេសសល់ណាខ្លះដែលបានស្វែងរកដើម្បីឲ្យទទួលយក ដែលជាប់ទាក់ទងនឹងវគ្គសវនាការទាំងបួនដំបូងនេះដែលខ្លួនជំទាស់ និងសម្អាងហេតុសម្រាប់ការតវ៉ាទាំងនេះ។ អង្គជំនុំជម្រះបានបញ្ជាក់ដោយប្រយ័ត្នថា ខណៈដែលការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងការជំទាស់ដូច្នេះ នឹងមិនអនុញ្ញាតអង្គជំនុំជម្រះ នឹងផ្តល់ឱកាសឲ្យមានសវនាការដេញដោលអំពីភាពអាចទទួលយកបាននៃឯកសារនៅក្នុងសវនាការទេ[8]។

៩- ដើម្បីជាប្រយោជន៍នៃប្រសិទ្ធភាពជាអតិបរមានៅក្នុងសវនាការលើអង្គសេចក្តី សហព្រះរាជអាជ្ញាទទូចដល់អង្គជំនុំជម្រះសាលាដំបូង កំណត់កាលបរិច្ឆេទសម្រាប់សវនាការដេញដោលផ្ទាល់មាត់ស្តីពីការជំទាស់ចំពោះភស្តុតាងជាឯកសារឲ្យបានឆាប់តាមដែលអាចធ្វើបាន នៅក្នុងដំណាក់កាលដំបូងនៃសវនាការនេះ។ ការណ៍នេះ ធ្លាប់បានលើកជាយោបល់ម្តងហើយពីមុន នៅក្នុង*សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបង្កើតប្រព័ន្ធប្រសិទ្ធភាពមួយ សម្រាប់ការទទួលយកភស្តុតាងនៅសវនា*

---

[8] **E131/1** បញ្ជីឈ្មោះសាក្សី សម្រាប់សវនាការដំណាក់កាលដំបូង កាលបរិច្ឆេទសម្រាប់ដាក់ការជំទាស់នឹងភាពអាចទទួលយកបាននៃភស្តុតាង និងវត្ថុតាង និងចម្លើយតបទៅនឹងញត្តិ E109/5 ចុះថ្ងៃទី២៥ តុលា ២០១១ ។

*ការ*[9] ដែលអង្គជំនុំជម្រះបានបញ្ជាក់ថា នឹងយកទៅពិចារណានៅក្នុងបរិបទនៃការគ្រប់គ្រងសវនាការដែលកំពុងដំណើរការ[10]។

១០- សវនាការផ្ទាល់មាត់ ស្តីពីភាពអាចទទួលយកបាននៃឯកសារក្នុងដំណាក់កាលដំបូងនៃការជំនុំជម្រះនេះ នឹងពន្លឿនកិច្ចដំណើរការនីតិវិធី តាមរយៈការអនុញ្ញាតឲ្យភាគីបង្ហាញភ័ស្តុតាងឯកសារកាន់តែមានប្រសិទ្ធភាព ក្នុងពេលសវនាការជំនុំជម្រះលើអង្គសេចក្តី និងជាជំនួយដ៏ធំធេងក្នុងការផ្តោតទៅលើវិសាលភាពនៃការសួរដេញដោលសាក្សី តាមរយៈការកំហិតព្រំដែននៃភ័ស្តុតាងដែលនឹងត្រូវលើកមកសំអាងតាមរយៈសក្ខីកម្មផ្ទាល់មាត់។

១១- មានការគិតទុកជាមុនថា រយៈពេលចំនួនប្រាំថ្ងៃរបស់តុលាការនេះ គឺមុខជានឹងផ្តល់នូវពេលវេលា និងឱកាសគ្រប់គ្រាន់សម្រាប់ឲ្យតុលាការស្តាប់សាក្សីនីមួយៗ និងពិចារណាទៅលើការជំទាស់សំខាន់ៗទាក់ទងនឹងឯកសារនានាដែលខំស្វែងរក ដើម្បីឲ្យទទួលយកដែលទាក់ទងនឹង៤វគ្គដំបូងនៃសវនាការជំនុំជម្រះក្តី។ សហព្រះរាជអាជ្ញានឹងស្នើសុំឲ្យសវនាការនេះ បានប្រព្រឹត្តទៅនៅក្នុងអំឡុងសប្តាហ៍ទីមួយនៃខែកុម្ភៈ ឆ្នាំ២០១២ បន្ទាប់ពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ ដែលជាកាលបរិច្ឆេទកំណត់សម្រាប់ការទទួលនូវការជំទាស់របស់ភាគីនានា។

## V. ដំណោះស្រាយដែលស្នើសុំ

១២- អាស្រ័យដោយមូលហេតុខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះ៖

(១) ចេញនៅមុនថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ នូវដីកាបណ្តោះអាសន្នមួយ ដើម្បីកោះអញ្ជើញសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលនៅសល់ទាក់ទងនឹងវគ្គទីមួយនៃសវនាការលើកដំបូង។ សុំឲ្យកំណត់វិសាលភាព និងពេលវេលាកំណត់សម្រាប់វគ្គទីពីរ និងកំណត់

---

[9] E136 សំណើរបស់សហព្រះរាជអាជ្ញាសុំបង្កើតប្រព័ន្ធមានប្រសិទ្ធភាពមួយសម្រាប់ទទួលយកភ័ស្តុតាងឯកសារនៅពេលសវនាការ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ (ជូនដំណឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១) ច្បាប់ចម្លងសមរម្យមួយត្រូវបានផ្ញើជូនអង្គជំនុំជម្រះ និងភាគីនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១១។

[10] **E145** សេចក្តីជូនដំណឹងរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការសម្រេចលើញត្តិដែលនៅសេសសល់មុនសវនាការ(E20, E132, E134, E135, E124/8, E124/9, E124/10, E136 និង E139) និងការណែនាំបន្ថែមដល់មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី, 29 វិច្ឆិកា 2011។

អត្តសញ្ញាណសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនានាដែលមានសក្តានុពល សម្រាប់វគ្គទីពីរនេះ យ៉ាងហោចណាស់ក៏សម្រាប់អម្លុងពេលដែលគ្រូបដណ្តប់ នៅក្នុងវគ្គទីពីរនៃសវនាការ ពីថ្ងៃទី១០ ខែមករា ដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ដែរ។

(២) ដកអ្នកជំនាញមួយរូប និងសាក្សីបួននាក់ ដែលទាក់ទងជាសំខាន់ទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីក្នុង*ផ្នែកនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន សម្រាប់សវនាការលើកដំបូងនៃសំណុំរឿងលេខ ០០២* និង

(៣) ផ្តល់ពេលសវនាការចំនួនមួយសប្តាហ៍ សម្រាប់គោលបំណងធ្វើការដេញដោលដោយផ្ទាល់មាត់ ស្តីពីភាពអាចទទួលយកបាននៃឯកសារនានា ដែលមានរយៈពេលប្រាំថ្ងៃនៅក្នុងអម្លុងពីថ្ងៃទី៦ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |